វិចារណកថា NEW YORK TIMES

ការកពប់ប្រេងនៅឈូងសមុទ្រ ដំណាក់កាលទី2

បោះពុម្ពផ្សាយ៖ ថ្ងៃទី13ខែមិនា ឆ្នាំ2011

នៅពេលដែល លោកKenneth Feinberg ដែលជាអ្នកគ្រប់គ្រងមូលនិធិសម្រាប់ជនរងគ្រោះ9/11 ជិតមួយទសវត្សកន្លងទៅ បានសួរខ្លួនគាត់ពីមូលហេតុដែលគាត់បានធ្វើការស្ម័គ្រចិត្តដើម្បីចាត់ចែងលើសំណង $20កោដ្ឋដុល្លារសម្រាប់ជនរងគ្រោះនៃការកំពប់ប្រេងនៅឈូងសមុទ្រម៉ិកស៊ិក។ គាត់មិនសូវបានឮអ្វីច្រើនក្រៅពីការរិះគន់—ខ្លះមានហេតុផលនិងមានប្រយោជន៍ចំណែកឯខ្លះទៀតមិនយុត្តិធម៌ហើយគ្មានប្រយោជន៍—តាំងពីពេលចាប់ផ្តើម។

អ្នករស់នៅតំបន់តាមឆ្នេរសមុទ្របានត្អូញត្អែរពីភាពយឺតយ៉ាវនិងការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់ចំពោះពួកគេ។ តំណាងរាស្ត្រ Jo Bonner មកពីគណៈបក្សសាធារណៈរដ្ឋនៅAlabama នាពេលថ្មីៗនេះបានហៅកម្មវិធីថា«បិសាច»និងហៅលោកFeinberg ថាជា«មនុស្សកំណាញ់»។ មានម្តងនោះ កាសែតMobile បានសុំឱ្យសេតវិមានបណ្តេញគាត់ចេញពីការងារ។ ហើយឥឡូវនេះក្រុមហ៊ុនBP ជាម្ចាស់ប្រាក់ដែលលោកFeinberg កំពុងតែធ្វើការបែងចែកបានអះអាងថាលោកFeinberg ជាមនុស្សចិត្តល្អជ្រុល។

ដូចអ្វីដែលគាត់គួរធ្វើ លោកFeinberg បានជំរុញការងារទៅមុខដោយធ្វើការកែតម្រូវនៅការងារពាក់កណ្តាល នៅក្នុងគោលការណ៍នៃកម្មវិធីដែលគាត់គួរតែធ្វើផងដែរ។ មកដល់ត្រឹមថ្ងៃទី10ខែមិនាគាត់បានផ្តល់ប្រាក់3.6កោដ្ឋដុល្លារទៅឱ្យអ្នកប្តឹងទាមទារសំណងចំនួន170,000នាក់នៅទូទាំងរដ្ឋទាំងប្រាំដែលនៅជាប់ឈូងសមុទ្រក្នុងនោះភាគច្រើនជា«ការបង់ប្រាក់ឱ្យភ្លាមៗ»ដែលស្មើនឹងការបាត់បង់ប្រាក់ចំណូលចំនួន6ខែ។ ក្រសួងយុត្តិធម៌ដែលបានតាមដានលើកម្មវិធីយ៉ាងម៉ត់ចត់បានចេញសេចក្តីថ្លែងការណ៍ថាចំនួនទាំងនេះជា«ចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ទោះតាមការគិតគូរបៀបណាក៏ដោយ»។

រយៈពេលបង់ប្រាក់សម្រាប់ករណីបន្ទាន់បានចប់ទៅហើយ ឥឡូវនេះជាការចាប់ផ្តើមការងារនៃការទូទាត់ការបង់ប្រាក់ចុងក្រោយដែលវាជាការងារលំបាកជាងមុន។ អ្នកប្តឹងទាមទារមានរយៈពេល3ឆ្នាំក្នុងការដាក់ពាក្យប្តឹង។ គ្មាននរណាម្នាក់តម្រូវឱ្យទទួលការបង់ប្រាក់ចុងក្រោយទេ ប៉ុន្តែអ្នកដែលត្រូវបានតម្រូវ—ដូចនៅក្នុងកម្មវិធី9/11—បានបោះបង់សិទ្ធិរបស់ពួកគេក្នុងការប្តឹងក្រុមហ៊ុនBP។ ជាជម្រើស អ្នកប្តឹងទាមទារអាចទទួលបាននូវការសងប្រាក់«ក្នុងកំឡុងពេលអន្តរកាល»សម្រាប់ការខូចខាតដែលបានកើតមានឡើង ដោយមិនចាំបាច់បដិសេធសិទ្ធិរបស់ពួកគេក្នុងការប្តឹងឡើយ។

ការបង់ប្រាក់ក្នុងកំឡុងពេលអន្តរកាលគឺជាជម្រើសដ៏មានសារៈសំខាន់។ សភាវគតិរបស់លោក Feinberg នឹងលើកទឹកចិត្តរបស់ប្រជាជនឱ្យទទួលយកនូវដំណោះស្រាយចុងក្រោយ សរុបសេចក្តីទៅ គោលបំណងសំខាន់របស់កម្មវិធីគឺផ្តល់ផ្តល់នូវជម្រើសដ៏មានប្រសិទ្ធភាពសម្រាប់ពាក្យបណ្តឹងដែលប្រើរយៈពេលវែងហើយគំនិតនេះមានដំណើរការល្អបន្ទាប់ពី 9/11។

សូម្បីតែលោកFeinberg ក៏ទទួលស្គាល់ថាវាមានការលំបាកក្នុងការ ព្យាករណ៍ថាតើឈូងសមុទ្រនឹងត្រូវចំណាយពេលប៉ុន្មានក្នុងការត្រឡប់មករកភាពដើមវិញឬថាតើរយៈពេលយូរប៉ុណ្ណាទើបអាជីវកម្មដូចជាអ្នកចិញ្ចឹមបង្គាជាដើម នឹងត្រឡប់មកមានសុខភាពល្អវិញ។ ក្រសួងយុត្តិធម៌បានជំរុញឱ្យគាត់កុំលម្អៀងទៅលើទម្រង់តែមួយការសងប្រាក់និងប្រាកដថា ការប្តឹងជាស្ថីទីត្រូវបានធ្វើឡើងដោយយុត្តិធម៌និងមានប្រសិទ្ធភាព។

យើងខ្ញុំសង្ឃឹមថាលោកFeinberg នឹងមិនលំអៀង។ គាត់បានធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានមួយចំនួន
ចំពោះការជំរុញរបស់ក្រសួង។ ឧទាហរណ៍៖ រហូតដល់ពេលថ្មីៗនេះ
គាត់បានកម្រិតសិទ្ធិចំពោះអាជីវកម្មដែលប៉ះពាល់ដោយជាក់ស្តែងដែលទទួលរងដោយការកំពប់ប្រេង ដូចជាការនេសាទ
និងការតាំងទីលំនៅ។ ការនេះមិនរាប់បញ្ចូលអ្នកប្តឹងទាមទារណាពេលអនាគត់ ឧទាហរណ៍
ទន្តពេទ្យដែលនិយាយថាពួកគេចំណូលពីទេសចរណ៍។ លោកFeinberg ក៏បានសន្យាដោយភាពស្និទ្ធស្នាលនិងមធ្យោបាយមាន
តម្លាភាពចំពោះអ្នកដាក់ពាក្យជាបុគ្គលនីមួយៗ។

យុត្តិធម៌គួរតែបន្តផ្តល់មតិយោបល់ហើយលោកFeinberg គួរតែត្រូវបន្តស្តាប់។ ក្នុងពេលជាមួយគ្នានោះដែរ
អ្នកនយោបាយដែលបញ្ចេញប្រតិកម្មច្រើនអាចបង្ហាញនូវការអត់ធ្មត់មួយចំនួន។ បុគ្គលនិងអាជីវកម្មជិត250,000
បានពាក្យបណ្តឹងសម្រាប់ការសងប្រាក់ចុងក្រោយឬការបង់ប្រាក់នៅក្នុងកំឡុងពេលអន្តរកាលនិងមានមនុស្សជាច្រើនទៀត។
ការធ្វើឱ្យមានតុល្យភាពរវាងការបង់ប្រាក់ប្តឹងទាមទារនៅក្នុងស្ថានភាពបន្ទាន់និងធានាបាននូវភាពត្រឹមត្រូវ
គឺជាកិច្ចការដ៏លំបាកដោយមិនមានការធ្វើសកម្មភាព។